00644449

E9/415

# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ

ភាគីដាក់ឯកសារ: សហមេធាវីរបស់អ្នកស្រី អៀង ធីរិទ្ធ

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ២០១១

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សម្ងាត់

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ **សាធារណៈ / Public**

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**បញ្ជីឈ្មោះសាក្សី និង អ្នកជំនាញរបស់មេធាវីការពារក្តី អ្នកស្រី អៀង ធីរិទ្ធ**

---

**ដាក់ដោយ៖**

**សហមេធាវីរបស់ អៀង ធីរិទ្ធ**

លោក ផាត់ ពៅស៊ាង

កញ្ញា Diana ELLIS QC

**ផ្ញើជូន៖**

**អង្គជំនុំជម្រះសាលាដំបូង**

ចៅក្រម និល ណុន

ចៅក្រម ធូ មណី

ចៅក្រម យ៉ា សុខន

ចៅក្រម Silvia CARTWRIGHT

ចៅក្រម Jean-Marc LAVERGNE

**ផ្ញើជូន៖**

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Andrew CAYLEY

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

ពេជ្រ អង្គ

Elisabeth SIMONNEAU FORT

ឯកសារដើម
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 15 / 02 / 2011
ម៉ោង (Time/Heure): 15:50
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

១. នៅថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០១១ អង្គជំនុំជម្រះសាលាដំបូងបានប្រកាសថាខ្លួនបានទទួលបណ្តឹងនៃសំណុំរឿងលេខ ០០២ ហើយបានចង្អុលបង្ហាញនៅក្នុង "ដីកាបង្គាប់ឲ្យភាគីដាក់សម្ភារៈដើម្បីរៀបចំសវនាការ"[1] (ដីកា) ដែលបណ្តាភាគីទាំងអស់ត្រូវដាក់បញ្ជីឈ្មោះសាក្សីរបស់ខ្លួន ដោយអនុលោមតាមវិធាន ៨០ នៃវិធានផ្ទៃក្នុង។ នៅខណៈដែល មេធាវីការពារក្តី បានជំទាស់ថាសាលដីកា[2] របស់អង្គបុរេជំនុំជម្រះ នឹងមិនត្រូវចាត់ទុកថាជា "សាលដីកា" នោះបានទេ តាមន័យនៃវិធាន ៧៧(១៤) នៃវិធានផ្ទៃក្នុងនោះ។ ដីកាបង្គាប់របស់អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថាពេលវេលាកំណត់បានចាប់ផ្តើមគិតចាប់ពីថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០១១[3] ។

២. តទៅនេះ មេធាវីការពារក្តីអ្នកស្រី អៀង ធីរិទ្ធ (ជនជាប់ចោទ)សូមដាក់នូវបញ្ជីឈ្មោះសាក្សីរបស់ខ្លួនជូនអង្គជំនុំជម្រះសាលាដំបូង ដោយអនុលោមតាមដីកាបង្គាប់ខាងលើ។ ឈ្មោះសាក្សីទាំងឡាយត្រូវបានដាក់ដោយសហព្រះរាជអាជ្ញាអំពីបញ្ជីឈ្មោះសាក្សីរបស់ខ្លួន[4] ហើយដែលត្រូវបានលុបចេញពីបញ្ជីឈ្មោះនេះដើម្បីកុំឲ្យជាន់គ្នា។

៣. នៅដំណាក់កាលណាមួយ ប្រសិនបើអង្គជំនុំជម្រះសាលាដំបូង ឬ សហព្រះរាជអាជ្ញា មានបំណងដកសាក្សីមួយចំនួនចេញពីបញ្ជីឈ្មោះសាក្សីរបស់ កសពនោះ មេធាវីការពារក្តីសូមស្នើថាវាគប្បីតែត្រូវបានគេរកពិតមានថាតើសាក្សីទាំងអស់នេះមានការពាក់ព័ន្ធទៅនឹងរឿងក្តីដែរ ឬអត់។

៤. មេធាវីការពារក្តីសូមរក្សាសិទ្ធិដើម្បីកែប្រែនូវបញ្ជីឈ្មោះសាក្សីរបស់ខ្លួនក្នុងការកោះហៅសាក្សីដែលជាអ្នកបានផ្តល់សក្ខីកម្មនិង វត្ថុតាងផ្សេងៗដែលនឹងត្រូវដាក់នៅពេលសមស្របដោយសហព្រះរាជអាជ្ញា និងភាគីផ្សេងទៀត ហើយដែលមេធាវីការពារក្តីអាចនឹងជំទាស់បានចំពោះខ្លឹមសារនៃសក្ខីកម្មទាំងនោះ ។

---

[1] អ.ជ.ស.ជ, ដីកាបង្គាប់ឲ្យភាគីដាក់សម្ភារៈដើម្បីរៀបចំសវនាការ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០១១, ឯកសារលេខ:E9 ។

[2] អ.ជ.ប, សាលដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ និង នួន ជា ប្រឆាំងនឹងដីកាដំណោះស្រាយ, ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១, ឯកសារលេខ: D427/2/12

[3] កថាខណ្ឌទី ២នៃដីកាបង្គាប់ ។

[4] បញ្ជីឈ្មោះអ្នកជំនាញ សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីរបស់សហព្រះរាជអាជ្ញា រួមទាំងឧបសម្ព័ន្ធសម្ងាត់ទី១, ទី២, ទី៣, ទី៣ក, ទី៤ និងទី៥, ចុះថ្ងៃទី ២៨ ខែមករា ឆ្នាំ ២០១១, ឯកសារលេខ: E9/4 ។

៥. មេធាវីការពារក្ដីសូមដាក់ជូននូវឧបសម្ព័ន្ធភ្ជាប់មកជាមួយដោយសម្ងាត់ដែលមានឈ្មោះសាក្សី និងអ្នកជំនាញដែលមេធាវីការពារក្ដីរបស់ជនជាប់ចោទបានស្នើឡើង។

| ភាគី | កាលបរិច្ឆេទ | ឈ្មោះរបស់មេធាវី | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|---|
| សហមេធាវីរបស់អ្នកស្រី អៀង ធីរិទ្ធ | ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ២០១១ | ផាត់ ពៅស៊ាង<br>Diana ELLIS, QC | ភ្នំពេញ | [signature] P.P. |